THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**ភាសា**

ខ្មែរ

**ហេតុអ្វីបានជាយើងស្នើសុំឱ្យអ្នកបំពេញការស្ទង់មតិនេះ?**

ការស្ទង់មតិនេះ សួរសំណួរអំពីប្រធានបទដែលសំខាន់សម្រាប់សាលារបស់អ្នក ដូចជាសន្តិសុខ សុវត្ថិភាព និងការគាំទ្រសម្រាប់ការសិក្សារបស់សិស្ស។ សិស្សខ្លះក៏នឹងឃើញសំណួរដែលបានមកពីការស្ទង់មតិអំពីសុខមាលភាពផង ដែរ។ នៅពេលដែលយើងទទួលបានមតិកែលម្អអំពីប្រធានបទទាំងនេះពីសិស្សជាច្រើន យើងប្រហែលជាអាចដឹងអំពីអារម្មណ៍របស់សិស្ស។ អ្នកដឹកនាំក្រសួងអប់រំ និងសាលាអាចប្រើព័ត៌មាននេះដើម្បីជួយសាលាឱ្យបន្តនូវអ្វីដែលពួកគេធ្វើបានល្អ ហើយរកវិធីធ្វើឱ្យសាលាកាន់តែប្រសើរ ឡើង។ សិស្សក៏អាចមើលព័ត៌មានដើម្បីឱ្យកាន់តែដឹងថែមទៀតអំពីសាលារបស់ពួកគេ និងសាលាផ្សេងៗទៀត។

**អ្វីៗដែលត្រូវដឹង មុនពេលអ្នកបំពេញការស្ទង់មតិនេះ៖**

- បំពេញ ឬមិនបំពេញការស្ទង់មតិនេះ គឺស្រេចចិត្តអ្នក។
- សំណួរទាំងអស់គឺស្រេចចិត្ត។ អ្នកអាចឆ្លើយសំណួរខ្លះហើយមិនឆ្លើយសំណួរផ្សេងៗទៀត។
- ការឆ្លើយតបរបស់អ្នកនឹងមិនត្រូវបានប្រើដើម្បីវាយតម្លៃអ្នក គ្រូរបស់អ្នក ឬបុគ្គលិកសាលាផ្សេងទៀតទេ។
- ការឆ្លើយតបរបស់អ្នកគឺជាការសម្ងាត់។ នេះមានន័យថាគ្មាននរណាម្នាក់នៅក្នុងសាលារបស់អ្នកនឹងដឹងថាតើអ្នកបានបំពេញការស្ទង់មតិឬអត់នោះទេ ឬថាតើអ្នកឆ្លើយតបរបៀបណានោះទេ។ នៅពេលដែលទិន្នន័យត្រូវបានចែករំលែក ទាំងឈ្មោះរបស់អ្នក ឬព័ត៌មានដែលអាចឱ្យដឹងថាអ្នកជានរណា នឹងមិនដែលជាប់ទាក់ទងនឹងការឆ្លើយតបរបស់អ្នកឡើយ។
- ការស្ទង់មតិត្រូវចំណាយពេលបំពេញប្រហែល ១០ ទៅ ១៥ នាទី។ នៅពេលអ្នកចាប់ផ្តើមបំពេញការស្ទង់មតិនេះ អ្នកមិនអាចផ្អាក ហើយបំពេញបន្តទៀតបានទេ។ ប្រសិនបើអ្នកមិនអាចបញ្ចប់ក្នុងពេលម្តងបាន អ្នកអាចបំពេញសាជាថ្មីម្តងទៀត។ យើងនឹងរក្សាទុកនូវការស្ទង់មតិដែលបំពេញបានច្រើនបំផុតពីសិស្សម្នាក់ៗ។

ប្រសិនបើអ្នកមានសំណួរ ឬការបារម្ភអ្វី អំពីការស្ទង់មតិ សូមផ្ញើអ៊ីមែលមក schoolsurveys@philasd.org ឬទូរស័ព្ទទៅលេខ 215-400-6565។

សូមអរគុណ!

ការិយាល័យស្រាវជ្រាវ និងវាយតម្លៃក្រសួងអប់រំទីក្រុងទីក្រុងហ្វីឡាដែលហ្វ្យា

បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA

# PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

### ការស្ទង់មតិសុខុមាលភាពសិស្ស

**1. តើអ្នក យល់ស្រប ឬ មិនយល់ស្រប ប៉ុណ្ណា?**

| | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង | ខ្ញុំមិនដឹង |
|---|---|---|---|---|---|
| មនុស្សពេញវ័យមកពីសាលារបស់ខ្ញុំព្យាយាមស្គាល់ខ្ញុំ | ○ | ○ | ○ | ○ | ○ |
| មនុស្សពេញវ័យមកពីសាលារបស់ខ្ញុំយកចិត្តទុកដាក់ចំពោះខ្ញុំ | ○ | ○ | ○ | ○ | ○ |
| ឥឡូវនេះ មានមនុស្សពេញវ័យមកពីសាលារបស់ខ្ញុំ ដែលខ្ញុំអាចនិយាយទៅកាន់គាត់អំពីអារម្មណ៍របស់ខ្ញុំ។ | ○ | ○ | ○ | ○ | ○ |
| នៅសាលាមានវិធីផ្សេងៗសម្រាប់ធ្វើឱ្យសិស្សស្គាល់គ្នា | ○ | ○ | ○ | ○ | ○ |
| ខ្ញុំមានមិត្តនៅសាលា | ○ | ○ | ○ | ○ | ○ |
| សិស្សនៅសាលាដឹងថាខ្ញុំជានរណា | ○ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA

PHILLY SCHOOL EXPERIENCE SURVEY

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

## ការស្ទង់មតិសុខុមាលភាពសិស្ស

**2. កាលពីខែមុន នៅសាលា តើមានរឿងទាំងនេះកើតឡើងដែរឬទេ?**

| | អត់មានទេ | មាន | ខ្ញុំមិនដឹង | មិនពាក់ព័ន្ធ |
|---|---|---|---|---|
| ខ្ញុំបានរៀននូវអ្វីៗដែលខ្ញុំអាចធ្វើដើម្បីដោះស្រាយអារម្មណ៍របស់ខ្ញុំតាមរបៀបល្អៗ (ឧទាហរណ៍ អ្វីៗដែលខ្ញុំអាចធ្វើនៅពេលខ្ញុំខឹង សោកសៅ ព្រួយបារម្ភ ឬ តានតឹងចិត្ត)។ | ○ | ○ | ○ | ○ |
| មនុស្សពេញវ័យនៅសាលារបស់ខ្ញុំបានសួរខ្ញុំ ថាតើខ្ញុំយ៉ាងម៉េចដែរ។ | ○ | ○ | ○ | ○ |
| គ្រូម្នាក់បាននិយាយអ្វីៗដែលវិជ្ជមានមកកាន់ខ្ញុំ | ○ | ○ | ○ | ○ |
| គេបានប្រព្រឹត្តមកលើខ្ញុំដោយអយុត្តិធម៌ ដោយសារអ្វីមួយអំពីរូបខ្ញុំ (ឧទាហរណ៍ ពូជសាសន៍ ភេទ អត្តសញ្ញាណ របស់ខ្ញុំ ។ល។)។ | ○ | ○ | ○ | ○ |
| ខ្ញុំខ្លាចសិស្សឯទៀត | ○ | ○ | ○ | ○ |
| ខ្ញុំអាចដោះស្រាយអារម្មណ៍របស់ខ្ញុំតាមវិធីល្អៗ (ឧទាហរណ៍ ធ្វើឱ្យខ្លួនខ្ញុំស្ងប់នៅពេលខ្ញុំខឹង ឬ តានតឹងចិត្ត)។ | ○ | ○ | ○ | ○ |
| ខ្ញុំអាចប្រាប់នរណាម្នាក់ពីអារម្មណ៍របស់ខ្ញុំ | ○ | ○ | ○ | ○ |
| ខ្ញុំអាចជួយដោះស្រាយជម្លោះ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ     បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA

# PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

### ការស្ទង់មតិសុខុមាលភាពសិស្ស

**3. តើអ្នកមានអារម្មណ៍ដូចម្តេចថ្ងៃនេះ? ប្រសិនបើអ្នកត្រូវជ្រើសរើសមួយ តើអ្នកត្រូវការជំនួយអ្វីឥឡូវនេះ?**

- ◯ ទំនាក់ទំនងជាមួយអ្នកដទៃ
- ◯ គ្រប់គ្រងអារម្មណ៍ និង វេទនារម្មណ៍របស់ខ្ញុំ
- ◯ ដំណើរការព្រឹត្តិការណ៍ បច្ចុប្បន្ន
- ◯ បង្កើនការយល់ដឹងអំពីវប្ប ធម៌
- ◯ កំណត់ និងសម្រេច គោលបំណង
- ◯ គ្មានខាងលើ

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**បរិយាកាសសាលា**

**4. តើអ្វីៗទាំងនេះ ជាការពិតញឹកញាប់ប៉ុណ្ណា?**

| | មិនដែលសោះ | ដោយកម្រ | ម្ដងម្កាល | ស្ទើរតែគ្រប់ពេល ឬ គ្រប់ពេលវេលាទាំងអស់ |
|---|---|---|---|---|
| ខ្ញុំមានអារម្មណ៍ថា គេស្វាគមន៍ខ្ញុំនៅសាលារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ខ្ញុំរីករាយពេលនៅសាលា។ | ○ | ○ | ○ | ○ |
| សិស្សដទៃទៀតគោរពខ្ញុំ។ | ○ | ○ | ○ | ○ |
| ពេលខ្ញុំនៅសាលា ខ្ញុំមានអារម្មណ៍ថា គេទទួលស្គាល់ខ្ញុំ។ | ○ | ○ | ○ | ○ |
| អគារសិក្សាស្ថិតក្នុងស្ថានភាពល្អ។ | ○ | ○ | ○ | ○ |
| សាលាខ្ញុំជ្រះស្អាត។ | ○ | ○ | ○ | ○ |
| ទីធ្លាសាលា (កន្លែងក្មេងលេង និងចិញ្ចើមផ្លូវជុំវិញសាលា) ជ្រះស្អាត។ | ○ | ○ | ○ | ○ |
| កន្លែងអាហារដ្ឋាន ឬបន្ទប់ញ៉ាំអាហារថ្ងៃត្រង់ មានអារម្មណ៍ស្វាគមន៍។ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ    បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**បរិយាកាសសាលា**

**5. តើអ្វីៗទាំងនេះ ជាការពិតញឹកញាប់ប៉ុណ្ណា?**

| | មិនដែលសោះ | ដោយកម្រ | ម្ដងម្កាល | ស្ទើរតែគ្រប់ពេល ឬ គ្រប់ពេលវេលាទាំងអស់ |
|---|---|---|---|---|
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងតំបន់ជុំវិញសាលារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅពេលធ្វើដំណើរទៅ និងមកពីសាលា។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅតាមរបៀងសាលារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងថ្នាក់រៀនរបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងបន្ទប់ទឹកក្នុងសាលារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅតាមជណ្ដើរក្នុងសាលារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងអាហារដ្ឋានក្នុងសាលារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ　បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

### បរិយាកាសសាលា

នេះគឺជាអ្វីដែលយើងចង់មានន័យអំពីពាក្យ **ការសម្លុតធ្វើបាប** និង **ការយាយីៈ**:

**ការសម្លុតធ្វើបាប** កើតឡើងនៅពេលដែលនរណាម្នាក់ (សិស្ស ឬមនុស្សពេញវ័យ) ដែលនិយាយ ឬធ្វើអាក្រក់ ឬធ្វើឱ្យមានការឈឺចាប់ ម្តងហើយម្តងទៀត និងដោយចេតនាទៅលើបុគ្គលផ្សេងទៀតដែលពិបាកការពារខ្លួនឯង។

**ការយាយី** គឺជាការមិនស្វាគមន៍ដោយពាក្យសំដី តាមការសរសេរ ក្រាហ្វិក និង/ឬ កាយវិការ ដែលទាក់ទងនឹងភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ទំនោរផ្លូវភេទ ការបង្ហាញអត្តសញ្ញាណនៃភេទ ដើមកំណើត សាសនា ពិការភាព ជំនាញភាសាអង់គ្លេស ស្ថានភាពសេដ្ឋកិច្ចសង្គម ឬជំនឿនយោបាយ។

**6. តើអ្នក យល់ស្រប ឬ មិនយល់ស្រប កម្រិតណា?**

| | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| ប្រសិនបើខ្ញុំប្រាប់គ្រូ ឬ មនុស្សពេញវ័យផ្សេងទៀតនៅសាលានេះ ថាសិស្សផ្សេងទៀតបានសម្លុតធ្វើបាបខ្ញុំ ពួកគាត់នឹងព្យាយាមជួយខ្ញុំ។ | ○ | ○ | ○ | ○ |

**7. តើសិស្សត្រូវបានគេប្រព្រឹត្តអាក្រក់មកលើខ្លួននៅសាលាដែរឬទេ? (នេះរួមបញ្ចូលទាំង ការសម្លុតធ្វើបាប ឬ ការយាយី)។**

- ○ មិនដែលសោះ
- ○ ដោយកម្រ
- ○ ម្តងម្កាល
- ○ ស្ទើរតែគ្រប់ពេល ឬ គ្រប់ពេលវេលាទាំងអស់

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**បរិយាកាសសាលា**

**8. សិស្សត្រូវបានគេប្រព្រឹត្តអាក្រក់មកលើ (ត្រូវបានគេសម្លុតធ្វើបាប ឬ ត្រូវបានគេយាយី) ដោយយោងទៅលើ...**

| | បាទ/ចាស | ទេ |
|---|---|---|
| ជាតិសាសន៍/ជាតិព័ន្ធ ឬ ប្រវត្តិ របស់ពួកគេ | ○ | ○ |
| សាសនារបស់ពួកគេ | ○ | ○ |
| អត្តសញ្ញាណនៃភេទរបស់ពួកគេ | ○ | ○ |
| ទំនោរផ្លូវភេទរបស់ពួកគេ | ○ | ○ |
| ការនិយាយភាសាអង់គ្លេសរបស់ពួកគេបានល្អប៉ុណ្ណា | ○ | ○ |
| មានពិការភាព | ○ | ○ |

ត្រឡប់មកវិញ    បន្ទាប់

PHILLY SCHOOL EXPERIENCE SURVEY

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**បរិយាកាសសាលា**

**9. តើមានអ្វីមួយដូចខាងក្រោមនេះបានកើតឡើងចំពោះរូបអ្នកផ្ទាល់នៅក្នុងឆ្នាំនេះដែរឬទេ?**

| | មិនដែលសោះ | ម្តង | លើសពីម្តង | ជាច្រើនដង |
|---|---|---|---|---|
| សិស្សម្នាក់បានគំរាមកំហែង ឬយាយីខ្ញុំផ្ទាល់ពេលខ្ញុំនៅសាលា។ | ○ | ○ | ○ | ○ |
| សិស្សម្នាក់បានគំរាមកំហែង ឬយាយីខ្ញុំតាមអ៊ិនធ័រណិត ពេលខ្ញុំនៅសាលា ឬក្នុងអំឡុងពេលសិក្សាតាមអ៊ិនធ័រ ណិត។ | ○ | ○ | ○ | ○ |
| សិស្សម្នាក់បានវាយតប់ រុញ ឬ វាយខ្ញុំ ពេលខ្ញុំនៅសាលា។ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**អ្នកផ្តល់ឱវាទនៅសាលា**

**10. ឆ្នាំនេះ តើអ្នកបានជួបជាមួយអ្នកផ្តល់ឱវាទនៅសាលារបស់អ្នកដែរឬទេ?**

- បាទ/ចាស
- ទេ
- ខ្ញុំមិនស្គាល់អ្នកផ្តល់ឱវាទនៅសាលារបស់ខ្ញុំទេ។
- សាលារបស់ខ្ញុំគ្មានអ្នកផ្តល់ឱវាទនទេ។

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**បរិយាកាសបង្ហាត់បង្រៀន**

### 11. តើអ្វីៗទាំងនេះ ជាការពិតញឹកញាប់ប៉ុណ្ណា?

| | មិនដែលសោះ | ដោយកម្រ | ម្តងម្កាល | ស្ទើរតែគ្រប់ពេល ឬ គ្រប់ពេលវេលាទាំងអស់ |
|---|---|---|---|---|
| គ្រូរបស់ខ្ញុំចង់អោយខ្ញុំមានជោគជ័យ។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំមានការរំពឹងទុកខ្ពស់ចំពោះរូបខ្ញុំនៅសាលា។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំលើកទឹកចិត្តខ្ញុំឱ្យខិតខំ។ | ○ | ○ | ○ | ○ |
| សាលារបស់ខ្ញុំធ្វើបានតាមសេចក្តីត្រូវការសម្រាប់ការសិក្សារបស់ខ្ញុំ។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំគោរពខ្ញុំ។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំពិតជាស្តាប់នូវអ្វីៗដែលខ្ញុំត្រូវនិយាយ។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំពិតជាយកចិត្តទុកដាក់ចំពោះខ្ញុំ។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំមានឆន្ទៈផ្តល់ជំនួយបន្ថែមដល់ខ្ញុំ ប្រសិនបើខ្ញុំត្រូវការជំនួយ។ | ○ | ○ | ○ | ○ |
| គ្រូរបស់ខ្ញុំពន្យល់ព័ត៌មានតាមរបៀបដែលខ្ញុំអាចយល់។ | ○ | ○ | ○ | ○ |
| យ៉ាងហោចណាស់មានមនុស្សពេញវ័យម្នាក់នៅសាលាដែលខ្ញុំទុកចិត្ត។ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ    បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

### បរិយាកាសបង្ហាត់បង្រៀន

**12. តើអ្វីៗទាំងនេះកើតឡើងញឹកញាប់ប៉ុណ្ណានៅក្នុងថ្នាក់របស់អ្នក?**

| | មិនដែលសោះ | ដោយកម្រ |ម្តងម្កាល | ស្ទើរតែគ្រប់ពេល ឬ គ្រប់ពេលវេលាទាំងអស់ |
|---|---|---|---|---|
| ក្នុងថ្នាក់រៀនរបស់ខ្ញុំ យើងមានការមមាញឹក ហើយមិនខ្ជះខ្ជាយពេលវេលាទេ។ | ◯ | ◯ | ◯ | ◯ |
| នៅក្នុងថ្នាក់របស់ខ្ញុំ យើងរៀនច្រើនណាស់។ | ◯ | ◯ | ◯ | ◯ |
| គ្រូរបស់ខ្ញុំត្រូវប្រាកដថាខ្ញុំយល់មេរៀនសិនមុននឹងបង្រៀនអ្វីៗថ្មីទៀត។ | ◯ | ◯ | ◯ | ◯ |

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

## ការដឹកជញ្ជូន

**13. នៅថ្ងៃរៀនភាគច្រើន តើអ្នកទៅ និងមកពី សាលាដោយរបៀបណា?**

- ◯ ខ្ញុំដើរ។
- ◯ ខ្ញុំជិះកង់។
- ◯ ខ្ញុំជិះឡាន។
- ◯ ខ្ញុំជិះរថយន្តសាលា។
- ◯ ខ្ញុំជិះរថយន្តសាធារណៈ (រថយន្តក្រុង រថយន្តបរលើផ្លូវដែក ឬ រថភ្លើងក្រោមដី របស់ SEPTA)។
- ◯ ផ្សេងទៀត

ត្រឡប់មកវិញ | បន្ទាប់

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

## សុខភាព

សំណួរអំពីសុខភាពជួយយើងឱ្យដឹងថាតើកម្មវិធីដែលជួយសិស្សឱ្យញ៉ាំអាហារដែលមានសុខភាព និងទទួលការហាត់ប្រាណ ដំណើរការល្អដែរឬអត់។

**14. ក្នុងអំឡុងពេល ៧ ថ្ងៃ កន្លងទៅនេះ , តើអ្នកបានបញ្ចេញពលកម្មប៉ុន្មានថ្ងៃ ដែលមានរយៈពេលយ៉ាងហោចណាស់ ៦០ នាទី? (បូកម៉ោងទាំងអស់ដែលអ្នកបានបញ្ចេញសកម្ម ភាពអ្វីមួយដែលធ្វើឱ្យបេះដូងលោតញាប់ ឬធ្វើឱ្យអ្នកពិបាកដកដង្ហើម ដូចជា រត់ ជិះកង់ លេងកីឡា ឬ រាំ។)**

- ○ ០ ថ្ងៃ
- ○ ១ ទៅ ២ ថ្ងៃ
- ○ ៣ ទៅ ៤ ថ្ងៃ
- ○ ៥ ទៅ ៦ ថ្ងៃ
- ○ ទាំង ៧ ថ្ងៃ

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

## សុខភាព

សម្រាប់សំណួរទាំង ៤ ខាងក្រោមនេះ សូមគិតដល់ម្សិលមិញ ឬប្រសិនបើថ្ងៃនេះជាថ្ងៃច័ន្ទ សូមគិតដល់ថ្ងៃសុក្រមុន។

**15. ម្សិលមិញ តើអ្នកបានផឹកទឹកប៉ុន្មានដង? ឧទាហរណ៍ ផឹកនឹង កែវ ពែង ដប ឬ កន្លែងយកទឹកផឹក។**

- ◯ ០ ដង
- ◯ ១ ដង
- ◯ ២ ដង
- ◯ ៣ ដង
- ◯ ៤ ដង
- ◯ ៥ ដង ឬលើសពីនេះ

**16. ម្សិលមិញ តើអ្នកបានផឹកសូដា ភេសជ្ជៈម្យ៉ាងមានទឹកផ្លែឈើ (punch) ភេសជ្ជៈមានរសជាតិផ្លែឈើ (fruit-flavored drinks) តែទឹកកកផ្អែម ទឹកក្រូចឆ្មា ភេសជ្ជៈសម្រាប់កីឡា ឬ ភេសជ្ជៈប៉ូវកម្លាំង ប៉ុន្មានដង?**

- ◯ ០ ដង
- ◯ ១ ដង
- ◯ ២ ដង
- ◯ ៣ ដង ឬលើសពីនេះ

**17. ម្សិលមិញ តើអ្នកបានញ៉ាំផ្លែឈើប៉ុន្មានដង? រាប់តែផ្លែឈើស្រស់ កក កំប៉ុង និង ស្ងួត។ កុំរាប់ទឹកផ្លែឈើ។**

- ◯ ០ ដង
- ◯ ១ ដង
- ◯ ២ ដង
- ◯ ៣ ដង
- ◯ ៤ ដង
- ◯ ៥ ដង ឬលើសពីនេះ

**18. ម្សិលមិញ តើអ្នកបានញ៉ាំបន្លែប៉ុន្មានដង? រាប់បន្លែឆ្អិន និងឆៅ សាឡាត់ និង ដំឡូងបារាំងស្ងោ ដុត ឬ សង្កត់ឱ្យបែក។**

- ◯ ០ ដង
- ◯ ១ ដង
- ◯ ២ ដង
- ◯ ៣ ដង
- ◯ ៤ ដង
- ◯ ៥ ដង ឬលើសពីនេះ

**19. ក្នុងរយៈពេល ៣០ ថ្ងៃ កន្លងទៅនេះ តើអ្នកបានអត់ឃ្លានញឹកញាប់ប៉ុណ្ណា ដោយសារគ្មានអាហារគ្រប់គ្រាន់នៅក្នុងផ្ទះរបស់អ្នក?**

- ◯ មិនដែលសោះ
- ◯ ដោយកម្រ
- ◯ ជួនកាល
- ◯ ភាគច្រើន
- ◯ តែងតែ

ត្រឡប់មកវិញ | បន្ទាប់

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**អាហារថ្ងៃត្រង់នៅសាលា**

**20. តើអ្នកញ៉ាំអាហារថ្ងៃត្រង់នៅសាលាប្រហែលប៉ុន្មានដងក្នុងមួយសប្តាហ៍?**

- ◯ ០ ដង
- ◯ ១ ទៅ ២ ដង
- ◯ ៣ ទៅ ៥ ដង

**21. តើអ្វីៗទាំងនេះ ជាការពិតញឹកញាប់ប៉ុណ្ណា?**

| | មិនដែលសោះ | ដោយកម្រ |ម្តងម្កាល | ស្ទើរតែគ្រប់ពេល ឬគ្រប់ពេលវេលា |
|---|---|---|---|---|
| អាហារមានរសជាតិឆ្ងាញ់។ | ◯ | ◯ | ◯ | ◯ |
| អាហារត្រូវបានចម្អិនតាមសីតុណ្ហភាពត្រឹមត្រូវ (ឧទាហរណ៍ អាហារក្តៅៗមិនត្រូវបានឱ្យញ៉ាំត្រជាក់ទេ)។ | ◯ | ◯ | ◯ | ◯ |

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

### បច្ចេកវិទ្យា

**22. ប្រសិនបើត្រូវការ តើអ្នកអាចទទួល Chromebook ឬ ឧបករណ៍ផ្សេងទៀតដែលសាលាចេញឱ្យដែរឬទេ?**

- ◯ អាច
- ◯ មិនអាចទេ
- ◯ មិនច្បាស់

**23. តើអ្នកមានបញ្ហាជាមួយការតភ្ជាប់ទៅអ៊ីនធឺណិតញឹកញាប់ប៉ុណ្ណា នៅពេលដែលអ្នកនៅផ្ទះធ្វើកិច្ចការសាលា ឬ កិច្ចការដែលគ្រូដាក់ឲ្យធ្វើ?**

- ◯ មិនដែលសោះ
- ◯ ដោយកម្រ
- ◯ម្តងម្កាល
- ◯ ស្ទើរតែគ្រប់ពេល ឬគ្រប់ពេលវេលា

ត្រឡប់មកវិញ | បន្ទាប់

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**ការបង្កើនបទពិសោធន៍ មហាវិទ្យាល័យ និងអាជីព**

**24. តើអ្នកយល់ស្របនឹងសេចក្តីថ្លែងខាងក្រោមនេះកម្រិតណា?**

| | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| នៅសាលារបស់ខ្ញុំ សិស្សមានឱកាសចូលរួមជាមួយក្រុមកីឡា។ | ◯ | ◯ | ◯ | ◯ |
| នៅសាលារបស់ខ្ញុំ សិស្សមានឱកាសចូលរួមជាមួយក្លឹប ផ្សេងៗ ឬក្រុមនៅខាងក្រៅថ្នាក់រៀន។ | ◯ | ◯ | ◯ | ◯ |
| នៅសាលារបស់ខ្ញុំ សិស្សមានឱកាសចូលរួមជាមួយ GSA ក្រុមខ្ទើយ និង មិនខ្ទើយ ឬក្រុមភេទ និងអត្តសញ្ញាណផ្លូវភេទ (Gay-Straight Alliance or Genders and Sexualities Alliance) ឬក្លឹបដែលស្រដៀងគ្នា។ | ◯ | ◯ | ◯ | ◯ |
| សាលារបស់ខ្ញុំកំពុងជួយរៀបចំខ្ញុំសម្រាប់មហាវិទ្យាល័យ។ | ◯ | ◯ | ◯ | ◯ |
| សាលារបស់ខ្ញុំកំពុងជួយខ្ញុំរៀបចំសម្រាប់ អាជីព/ផ្លូវទៅកាន់អាជីព។ | ◯ | ◯ | ◯ | ◯ |

ត្រឡប់មកវិញ　　បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**ភ្នាក់ងារផ្នែកសុវត្ថិភាពសាលា**

**25. តើសាលារបស់អ្នកមានភ្នាក់ងារផ្នែកសុវត្ថិភាពសាលា (ភ្នាក់ងារប៉ូលិសសាលា) ដែរឬទេ?**

- ◯ មាន
- ◯ អត់មានទេ
- ◯ ខ្ញុំមិនដឹង

ត្រឡប់មកវិញ | បន្ទាប់

PHILLY SCHOOL EXPERIENCE SURVEY

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**ភ្នាក់ងារផ្នែកសុវត្ថិភាពសាលា**

**26. តើអ្នកយល់ស្របនឹងសេចក្តីថ្លែងខាងក្រោមនេះកម្រិតណា?**

| | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| ខ្ញុំទុកចិត្តលើភ្នាក់ងារផ្នែកសុវត្ថិភាពសាលា។ | ○ | ○ | ○ | ○ |
| ខ្ញុំមានអារម្មណ៍ថាទទួលការគោរពពីភ្នាក់ងារផ្នែកសុវត្ថិភាពសាលា។ | ○ | ○ | ○ | ○ |
| ភ្នាក់ងារផ្នែកសុវត្ថិភាពសាលាជួយសិស្សឱ្យស្ងប់ស្ងាត់នៅពេលពួកគេមានបញ្ហា។ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA

PHILLY SCHOOL EXPERIENCE SURVEY

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

## ភាពចម្រុះ សមធម៌ និង ការរួមបញ្ចូល

សំណួរខាងក្រោមនេះគឺជាផ្នែកមួយនៃការងាររបស់យើងឆ្ពោះទៅរកការក្លាយជាអង្គការប្រឆាំងនឹងការរើសអើងជាតិសាសន៍។ សំណួរទាំងនេះស្តីអំពីភាពចម្រុះ សមធម៌ និងការរួមបញ្ចូល។ យើងសួរសំណួរស្រដៀងគ្នាទៅ នាយកសាលា គ្រូបង្រៀន បុគ្គលិកគាំទ្រសាលា សិស្ស និង ឪពុកម្តាយ/អាណាព្យាបាល។ ចម្លើយរបស់អ្នកចំពោះសំណួរទាំងនេះជួយយើងឱ្យយល់ពីចំណុចខ្លាំងរបស់យើង និងឱកាសសម្រាប់ការផ្លាស់ប្តូរ។

ភាពចម្រុះ យើងមានន័យថាមានភាពខុសគ្នាក្នុងចំណោមក្រុមមនុស្ស និងបុគ្គលដែលផ្អែកលើលក្ខណៈអត្តសញ្ញាណ ដូចជា សញ្ជាតិ ពូជសាសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គម (ឬ វណ្ណៈ) ភេទ លក្ខណៈពិសេស ភាសា សាសនា ទំនោរផ្លូវភេទ និងទីកន្លែងដែលពួកគេរស់នៅ គ្រាន់តែរៀបរាប់មួយចំនួនប៉ុណ្ណោះ។

សមធម៌ យើងសំដៅទៅលើ គោលការណ៍ ការអនុវត្តន៍ និង ឱកាសស្មើភាព សម្រាប់សមាជិកទាំងអស់នៃសហគមន៍ក្រសួងអប់រំរបស់យើង ហើយជាពិសេសសម្រាប់សមាជិកនៃក្រុមដែលមានប្រវត្តិត្រូវបានគេប្រព្រឹត្តិមកលើដោយមិនត្រឹមត្រូវ។

ការរួមបញ្ចូល យើងមានន័យថា តើបុគ្គលម្នាក់ៗមានអារម្មណ៍ថាមានតម្លៃប៉ុណ្ណាតាមការទាក់ទង និងចូលរួមជាសមាជិកនៃសហគមន៍សាលា។

### 27. តើអ្វីៗទាំងនេះកើតមានឡើងញឹកញាប់ប៉ុនណា?

| | មិនដែលសោះ | កម្រមាន | ម្តងម្កាល | ស្ទើរតែគ្រប់ពេល ឬគ្រប់ពេលវេលា |
|---|---|---|---|---|
| ខ្ញុំចំណាយពេលនៅសាលាជាមួយសិស្សានុសិស្សដែលមាន ជាតិសាសន៍ ជាតិព័ន្ធ ឬ វប្បធម៌ ខុសៗគ្នា | ○ | ○ | ○ | ○ |
| សិស្សានុសិស្សនៅសាលារបស់ខ្ញុំប្រព្រឹត្តិចំពោះអ្នកដែលមាន ជាតិសាសន៍ ជាតិព័ន្ធ ឬ វប្បធម៌ ខុសៗគ្នា ដោយត្រឹមត្រូវ | ○ | ○ | ○ | ○ |
| មនុស្សពេញវ័យនៅសាលារបស់ខ្ញុំប្រព្រឹត្តិចំពោះអ្នកដែលមាន ជាតិសាសន៍ ជាតិព័ន្ធ ឬ វប្បធម៌ ខុសៗគ្នា ដោយត្រឹមត្រូវ | ○ | ○ | ○ | ○ |
| គ្រូជំរុញខ្ញុំឱ្យស្វែងយល់អំពីអ្នកដែលមាន ជាតិសាសន៍ ជាតិព័ន្ធ ឬ វប្បធម៌ ខុសៗគ្នា | ○ | ○ | ○ | ○ |

| | មិនដែលសោះ | កម្រមាន | ម្តងម្កាល | ស្ទើរតែគ្រប់ពេល ឬគ្រប់ពេលវេលា |
|---|---|---|---|---|
| សិស្សនៅសាលារបស់ខ្ញុំមានការសន្ទនាសំខាន់ៗជាមួយគ្នាទៅវិញទៅមកអំពី ជាតិសាសន៍ ទោះបីជានៅពេលដែលការសន្ទនានោះប្រហែលជាមិនស្រួលក៏ដោយ។ | ○ | ○ | ○ | ○ |
| នៅពេលណាមានព្រឹត្តិការណ៍ព័ត៌មានសំខាន់ៗទាក់ទងនឹងពូជសាសន៍ មនុស្សពេញវ័យនៅសាលារបស់ខ្ញុំនិយាយអំពីព័ត៌មានទាំងនេះជាមួយសិស្ស។ | ○ | ○ | ○ | ○ |

**28. តើអ្នកយល់ស្របនឹងអ្វីៗខាងក្រោមនេះកម្រិតណា?**

| | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|
| គ្រូរបស់ខ្ញុំយកចិត្តទុកដាក់ចំពោះវប្បធម៌ ជាតិសាសន៍ និងអត្តសញ្ញាណរបស់ខ្ញុំ | ○ | ○ | ○ | ○ |
| សិស្សនៅសាលារបស់ខ្ញុំមានមិត្តជិតស្និទ្ធដែលមាន ជាតិសាសន៍ ជាតិព័ន្ធ ឬវប្បធម៌ ខុសៗគ្នា។ | ○ | ○ | ○ | ○ |

ត្រឡប់មកវិញ | បន្ទាប់

ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**ព័ត៌មានរបស់សិស្ស**

សំណួរទាំងនេះជួយយើងឱ្យដឹងថាតើសិស្សដែលមានលក្ខណៈខុសៗគ្នាមានចម្លើយដូចគ្នា ឬ ខុសគ្នា ចំពោះសំណួរនៅក្នុងការស្ទង់មតិនេះ។

**29. តើអ្នកមាន ជាតិសាសន៍/ជាតិព័ន្ធ អ្វី? (ជ្រើសរើសអ្វីៗដែលពាក់ព័ន្ធទាំងអស់)**

- ☐ ស្បែកស
- ☐ ស្បែកខ្មៅ/អាហ្វ្រិក អាមេរិកាំង
- ☐ អេស្ប៉ាញ/ឡាតាំង
- ☐ អាស៊ី ឬ អាស៊ី អាមេរិកាំង
- ☐ ជនជាតិដើមអាមេរិកាំង ឬ ជនជាតិដើមអាឡាស្កា
- ☐ ជនជាតិដើមហាវៃ ឬ អ្នកកោះប៉ាស៊ីហ្វិក ផ្សេងទៀត។
- ☐ ផ្សេងទៀត
- ☐ ខ្ញុំមិនចង់ឆ្លើយតបទេ

នៅពេលដែល ភេទ (sex) និង ភេទតាមអារម្មណ៍ (gender) របស់មនុស្សម្នាក់មិនត្រូវគ្នា ពួកគេប្រហែលជាគិតថាខ្លួនឯងជាអ្នកប្តូរភេទ (ប្រុស/ស្រីប្តូរភេទ)។ Sex គឺជាភេទដែលមនុស្សកើតមក។ Gender គឺជាភេទតាមអា រម្មណ៍របស់មនុស្ស។

**30. តើអត្តសញ្ញាណនៃភេទតាមអារម្មណ៍របស់អ្នកគឺជាអ្វី?**

- ◯ ប្រុស
- ◯ ស្រី
- ◯ ប្រុសប្តូរភេទ
- ◯ ស្រីប្តូរភេទ
- ◯ មិនមែនស្រី ឬប្រុស/ការមិនយល់ស្របតាមភេទរបស់ខ្លួន (Non-binary/gender non-conforming)
- ◯ ខ្ញុំមិនប្រាកដទេ
- ◯ ខ្ញុំមិនចង់ឆ្លើយតបទេ
- ◯ ផ្សេងទៀត

យើងដឹងថាមានពាក្យជាច្រើនដែលមនុស្សប្រើដើម្បីពណ៌នាអំពីទំនោរផ្លូវភេទរបស់ពួកគេ។

**31. ក្នុងចំណោមពាក្យខាងក្រោមនេះ តើមួយណាត្រូវតាមចំ ណង់ផ្លូវភេទរបស់អ្នកបំផុត?**

- ◯ ប្រុសស្រឡាញ់ប្រុស
- ◯ ស្រីស្រឡាញ់ស្រី
- ◯ ទ្វេរភេទ
- ◯ ស្រឡាញ់ភេទផ្ទុយគ្នា
- ◯ ផ្សេងទៀត
- ◯ ខ្ញុំមិនប្រាកដទេ
- ◯ ខ្ញុំមិនចង់ឆ្លើយតបទេ

ត្រឡប់មកវិញ | បន្ទាប់

THE SCHOOL DISTRICT OF PHILADELPHIA
PHILLY SCHOOL EXPERIENCE SURVEY

# ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**ការសួរនាំបន្តអំពីការស្ទង់មតិ**

**32. តើអ្នកចង់ទទួលសេចក្តីសង្ខេបនៃលទ្ធផល DWS របស់សាលាអ្នកតាមរយៈអ៊ីមែល នៅពេលមានលទ្ធផលទាំងនោះដែរឬទេ ?**

- ◯ ចង់
- ◯ មិនចង់ទេ

**33. ការិយាល័យស្រាវជ្រាវ និងវាយតម្លៃ តែងតែស្វែងរកនូវការស្វែងយល់បន្ថែមអំពីប្រធានបទដែលយើងសួរនៅក្នុងការស្ទង់មតិ។ តើអ្នកដឹងអំពីឱកាសចូលរួមក្នុង ក្រុមពិភាក្សា ការសម្ភាសន៍ ឬការស្ទង់មតិផ្សេងទៀតនៅពេលអនាគតដែរឬទេ?**

- ◯ ចង់
- ◯ មិនចង់ទេ

ត្រឡប់មកវិញ | បន្ទាប់

PHILLY SCHOOL EXPERIENCE SURVEY

## ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា ឆ្នាំ ២០២២-២៣ សម្រាប់សិស្ស (ថ្នាក់ទី ៣ ដល់ ទី ១២)

**សូមអរគុណ!**

សូមអរគុណចំពោះការបំពេញការស្ទង់មតិនេះ!

ប្រសិនបើអ្នកមានបញ្ហាអ្វីមួយដែលត្រូវដោះស្រាយភ្លាមៗ សូមប្រាប់គ្រូរបស់អ្នក អ្នកផ្តល់ឱវាទ ឬមនុស្សពេញវ័យផ្សេងទៀតនៅសាលារបស់អ្នក។

សូមចុចលើពាក្យ DONE (រួចរាល់) ដើម្បីបញ្ជូនចម្លើយរបស់អ្នក។

ត្រឡប់មកវិញ | Submit / ទៅទំព័រចាប់ផ្តើមសរទេះធ្វើទាន់